សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីដំណោះស្រាយបញ្ហាព្រំដែនខ្មែរ ជាមួយប្រទេសជិតខាង

web site: hoksavann.org

ថ្ងៃទី១៨ ឧសភា ២០០៥

ប្រជាពលរដ្ឋគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក តែងតែរក្សាបូរណភាពទឹកដី ឯករាជ្យ និងអធិបតេយ្យភាពរបស់ខ្លួនឲ្យបានគង់វង់មិនឲ្យបាត់បង់ ។ ដូចនេះដែរ ប្រជាពលរដ្ឋខ្មែរនៃប្រទេសកម្ពុជានៅពេលនេះ ក៏នៅតែមានការព្រួយបារម្ភអំពីទឹកដីជាមត៌ករបស់ជាតិខ្លួន ដែលបានបាត់បង់ពីអតីតកាល ហើយបច្ចុប្បន្ននេះនៅតែបាត់បង់ជាបន្តទៅទៀតពីប្រទេសជិតខាង គឺប្រទេសវៀតណាមនិងប្រទេសថៃ ។ មហិច្ឆិតារបស់ប្រទេសទាំងពីរនេះ ជាចរិតប្រពៃណីរបស់ពួកគេដែលពុំអាចកែប្រែបាន ដែលបានរំលោភយកទឹកដីខ្មែរតាំងពីដើមមក ។ ការរំលោភយកទឹកដីខ្មែរពីប្រទេសជិតខាងជារឿងមួយ ប៉ុន្តែរឿងសំខាន់នៅត្រង់អ្នកដឹកនាំខ្មែរចាត់ការមានចន្លោះប្រហោង ដែលអាចឲ្យគេជ្រៀតចូលយកទឹកដីខ្មែរបាន ជាពិសេសគួរឲ្យស្តាយអ្នកដឹកនាំខ្មែរ បើកដៃឲ្យគេយកទឹកដីខ្មែរដោយត្រង់ៗតែម្តង ដោយប្តូរយកកូនក្រមុំយួន ដូចជាព្រះបាទជ័យជេដ្ឋាទី២ **ហើយឧទាហរណ៍ទី២នៅឆ្នាំ១៩៤៩ បារាំងបានប្រគល់ដីកម្ពុជាក្រោមទាំងមូលទៅប្រទេសវៀតណាម មតិប្រជាពលរដ្ឋខ្មែរឆ្ងល់ថា ហេតុអ្វីបានជាព្រះមហាក្សត្រខ្មែរ ដែលគ្រប់គ្រងប្រទេសកម្ពុជាពេលនោះ ពុំប្រឆាំងនឹងអាណានិគមនិយមបារាំង ដែលកាត់ទឹកដីខ្មែរឲ្យទៅវៀតណាមដោយអយុត្តិធម៌ ហើយទាមទារយកត្រឡប់មកវិញ ?** ។

ឥឡូវនេះមកដល់សតវត្សទី២០ឈានមកដល់សតវត្សទី២១ មេរៀនអតីតកាលវិលមកវិញដដែល ចរិតអ្នកដឹកនាំខ្មែរនៅតែដដែល គឺនៅតែហែកហួរគ្នា ប្តឹងប្តល់គ្នា យកឈ្នះចាញ់គ្នា នៅមុខប្រជាជាតិជិតខាងទាំងពីរ ដែលកំពុងរំលោភយកទឹកដីខ្មែរ សូម្បីប្រទេសលាវសព្វថ្ងៃនេះ ក៏មើលងាយខ្មែរដែរ ដោយមារយាទអ្នកដឹកនាំខ្មែរធ្វើឲ្យគេមើលងាយ ។ ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ជាពិសេសប្រជាពលរដ្ឋនៅតាមព្រំប្រទល់ដែនជាអ្នកស្នេហាទឹកដីរបស់ខ្លួន ខំស្រែកថាយួនរំកិលព្រំដែនចូលមកដីខ្មែរ បាត់បង់ដីស្រែរបស់ខ្លួនដែលធ្លាប់ធ្វើ ផ្ទុយទៅវិញអ្នកដឹកនាំខ្មែរឆ្លើយតបថា យួនពុំអាចឈ្លានពានរំកិលព្រំដែនចូលមកដីខ្មែរទេ ការឆ្លើយជំនួសយួនដូច្នេះ ធ្វើឲ្យអ្នកដឹកនាំយួនមានសង្ឃឹមកាន់តែមាំថា រដ្ឋាភិបាលខ្មែរធ្វើការឲ្យខ្លួន ហើយខ្លួនពុំចាំបាច់ឆ្លើយតបនឹងប្រជាពលរដ្ឋខ្មែរវិញទេ ហើយធ្វើឲ្យយួនមើលឃើញថា អ្នកដឹកនាំខ្មែរនិងប្រជាពលរដ្ឋខ្មែរបែកបាក់គ្នា ដែលតាមការល្អ អ្នកដឹកនាំខ្មែរមិនត្រូវឆ្លើយតបទៅនឹងប្រជាពលរដ្ឋរបស់ខ្លួនទេ គួរទៅសង្កេតពត៌មានដែលប្រជាពលរដ្ឋផ្តល់ឲ្យ ពិតឬពុំពិតក៏គួរនៅស្ងប់ស្ងៀម កុំចោទប្រជាពលរដ្ឋរបស់ខ្លួននៅឲ្យសត្រូវមើលងាយ ហើយចាប់ដោះស្រាយតាមយថាហេតុ ធ្វើយ៉ាងនេះទើបចាត់ទុកថា អ្នកកាន់អំណាចនិងប្រជាពលរដ្ឋរបស់ខ្លួនរួបរួមគ្នាដោះស្រាយបញ្ហាជាតិ ។ មួយទៀតគណៈកម្មការព្រំដែនខ្មែរនៅប្រទេសបារាំង និងគណៈកម្មការព្រំដែនមួយទៀតដែលមានទីតាំងនៅប្រទេសកម្ពុជា បានខំប្រឹងប្រែងប្រមូលឯកសារបានជាច្រើន ដែលបញ្ជាក់ថាប្រទេសទាំងបី វៀតណាម ថៃ និងលាវ បានរំលោភឈ្លានពានដីគោកនិងសមុទ្រខ្មែរ ប៉ុន្តែអ្នកកាន់អំណាចខ្មែរបច្ចុប្បន្ននេះ ព្រងើយកន្តើយមិនយកចិត្តទុកដាក់នឹងសកម្មភាពស្នេហាជាតិរបស់អង្គការក្រៅរដ្ឋាភិបាលទាំងនោះ ព្រមទាំងរាំងរាមិនឲ្យជួបប្រជុំគ្នា និយាយពីបញ្ហាព្រំដែននេះថែមទៀត ។ រាជរដ្ឋាភិបាលខ្មែរត្រូវតែដឹងដោយខ្លួនឯងថា បើខ្លួនជាតំណាងផលប្រយោជន៍ខ្មែរពិតប្រាកដ តោងតែប្រមូលគ្រប់កម្លាំងប្រជាពលរដ្ឋទាំងអស់ ដោយមិនត្រូវទាត់ចោលខ្មែរណាមួយ ដើម្បីបំរើផលប្រយោជន៍ជាតិមាតុភូមិ ទោះបីប៉ះប្រយោជន៍បរទេសដែលជួយខ្លួនឲ្យមានអំណាច កាលពីអតីតកាលក៏ដោយ ។

ឥឡូវនេះក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែនបានកើតឡើងដោយមានសមាជិក៧រូប ដែលមានសម្តេចនរោត្តម-សីហនុជាប្រធាន សមាជិក៦រូបទៀតយកពីតំណាងព្រឹទ្ធសភា តំណាងរដ្ឋសភា តំណាងរាជរដ្ឋាភិបាល និងតំណាងមួយរូបៗពីគណបក្សនយោបាយទាំងបី ។ តើក្រុមប្រឹក្សាជាន់ខ្ពស់នេះមានកម្លាំងគ្រប់គ្រាន់ សំរាប់ធ្វើការដោះស្រាយបញ្ហារំលោភទឹកដីខ្មែរពីសំណាក់ប្រទេសទាំងបីនេះបានឬទេ ? កិច្ចការដ៏សំខាន់នេះបានសំរេចជោគជ័យឬពុំបានសំរេច គឺស្ថិតនៅលើកាតព្វកិច្ចខ្មែរខ្លួនឯង ។ តើភាគីខ្មែរមានសុឆន្ទៈពិតប្រាកដក្នុងការរក្សាបូរណភាពទឹកដីរបស់ជាតិខ្លួនឲ្យបានគង់វង់ឬទេ ? បើឧត្តមគតិនេះមានហើយ ត្រូវសុខចិត្តធ្វើពលិកម្មលះបង់ប្រយោជន៍ផ្ទាល់ខ្លួននិងប្រយោជន៍របស់បក្សពួក ដោយរួមកម្លាំងគ្នារកគោលគំនិតនិងមធ្យោបាយរួម ដើម្បីទប់ទល់នឹងការរំលោភយកទឹកដីពីប្រទេសជិតខាង ដែលមានកម្លាំងដ៏ខ្លាំងក្លា ។ មួយទៀត ដើម្បីបង្កើតការទុកចិត្តគ្នាជាថ្មី ត្រូវលះបង់ការប្តឹងប្តល់គ្នា ឬដោយហោចណាស់ក៏ត្រូវផ្អាកមួយពេល ដើម្បីប្រមូលកម្លាំងរក្សាការពារទឹកដីជាមត៌កជាតិ ។ ដើម្បីឈ្នះអ្នកខាងក្រៅ លុះត្រាតែរួបរួមគ្នាឲ្យមានឯកភាពជាតិ ។ បើរួបរួមគ្នាហើយ ពុំដឹងជាធ្វើការបានជោគជ័យឬយ៉ាងណាទេ ព្រោះប្រទេសជិតខាងរបស់ខ្មែរមានកម្លាំងគ្រប់វិស័យជាងខ្មែរ ហើយជាប្រទេសពុំសូវគោរពច្បាប់ទម្លាប់ក្នុងបញ្ហានេះផង។ **តាមមតិអ្នកតាមដានពត៌មានពុំទាន់មានជំនឿថា ក្រុមប្រឹក្សាជាន់ខ្ពស់នេះអាចដោះស្រាយបញ្ហាព្រំដែនប្រកបដោយយុត្តិធម៌បានឡើយ** ដោយហេតុពីរយ៉ាងគឺ ទីមួយច្បាប់សំរាប់ឲ្យក្រុមប្រឹក្សាជាន់ខ្ពស់នេះអនុវត្តជាច្បាប់កើតឡើងពីរាជរដ្ឋាភិបាល គឺបក្សប្រជាជនកម្ពុជាតាក់តែងឡើង ឯបក្សហ៊្វុនស៊ិនប៉ិចគ្រាន់តែហែអើតាមបក្សប្រជាជនប៉ុណ្ណោះ ។ ក្នុងច្បាប់នោះគ្មានផ្តល់អំណាចដ៏សំខាន់ចាំបាច់ណាមួយ ឲ្យដល់ក្រុមប្រឹក្សាជាន់ខ្ពស់នោះឡើយ ដោយកម្រឹតព្រំដែន បើរកឃើញភស្តុតាងនឹងយល់បែបណា ត្រូវធ្វើរបាយការណ៍ទៅរាជរដ្ឋាភិបាលខ្មែរ ដោយគ្មានសិទ្ធិសំរេចបែបណាឡើយ ស្របតាមព្រះបន្ទូលរបស់សម្តេចនរោត្តម-សីហនុថា ព្រះអង្គគ្មានអំណាចនឹងសំរេចអ្វីឡើយក្នុងក្រុមប្រឹក្សាជាន់ខ្ពស់នេះ ។ មូលហេតុទីពីរ ក្រុមប្រឹក្សាជាន់ខ្ពស់នេះ ដែលអាចសំរេចអ្វីមួយយកជាបានការបាន លុះត្រាតែស្របគ្នាជាឯកច្ឆន្ទ ។ ពិបាករកឯកច្ឆន្ទណាស់ ព្រោះបក្សប្រជាជននៅតែប្រកាន់គោលជំហររក្សាទុកនូវសន្ធិសញ្ញាខុសច្បាប់ឆ្នាំ១៩៧៩និងសន្ធិសញ្ញាបីទៀតក្នុងអំឡុង១៩៨០ជាមួយវៀតណាម ពុំព្រមប្រកាសលុបចោល ហើយក្នុងពេលជាមួយគ្នានោះ វៀតណាមក៏ប្រកាសប្រកាន់គោលជំហរនេះដែរ ។ ចំណែកបក្សប្រឆាំង គឺបក្សសមរង្ស៊ី គណៈកម្មាធិការព្រំដែននៅប្រទេសបារាំងនិងនៅកម្ពុជា និងសម្តេចនរោត្តម-សីហនុ បានប្រកាសមិនទទួលស្គាល់សន្ធិសញ្ញានោះ ហើយ

ប្រកាសឲ្យលុបចោល ស្របតាមកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសប្រទេសបារាំងស្តីពីប្រទេសកម្ពុជា ថាទុកជាមោឃភាព គឺទុកជាឥតបានការ នូវសន្ធិសញ្ញាណាដែលបានចុះហត្ថលេខាមុនឆ្នាំ១៩៩១ ដែលធ្វើឲ្យប៉ះពាល់ដល់បូរណភាពទឹកដីនិងអធិបតេយ្យខ្មែរ ។ បើភាគីខ្មែរខ្លួនឯងរួមគំនិតឃោបល់គ្នាហើយ ទើបមានឥទ្ធិពលទៅចរចាជាមួយប្រទេសជិតខាងទាំងបី ។ ខ្មែរខ្លួនឯងត្រូវចេះធ្វើការដើម្បីជាតិរស់ ពុំមែនដើម្បីបក្សពួកណាមួយ ឬដើម្បីតម្រូវចិត្តបរទេសឲ្យបាត់ទឹកដីឡើយ ។ បើភាគីខ្មែរចរចាជាមួយភាគីប្រទេសជិតខាងពុំមានប្រសិទ្ធិភាពទេ មានតែពឹងផ្អែកលើច្បាប់អន្តរជាតិឲ្យរកយុត្តិធម៌ ក្នុងបញ្ហាព្រំដែនដីគោកនិងដីសមុទ្រនេះ ដើម្បីជៀសវាងចំបាំង ជាពិសេសពឹងផ្អែកទៅលើប្រទេសហត្ថលេខីទាំង១៨ដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីសឆ្នាំ១៩៩១ ស្តីពីកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជា ។ ប្រជាពលរដ្ឋខ្មែរទូទៅ ទាំងក្នុងប្រទេសនិងក្រៅប្រទេសរង់ចាំមើលដំណើរព្រឹត្តិការណ៍នៃក្រុមប្រឹក្សាជាន់ខ្ពស់នេះ ។៚